សូមមើលវីដេអូ ភាគទី ១

# សិក្សាព្រះអភិធម្ម

# បរមត្ថធម៌

ពាក្យថា **បរមត្ថ** មកពី **បរម** + **អត្ថ** = **បរមត្ថ**

**បរម** ប្រែថា ប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត

**អត្ថ** ប្រែថា អត្ថ, សេចក្តី ឬន័យ

រួមពាក្យទាំងពីរចូលគ្នា បានជា **បរមត្ថ** ប្រែថា អត្ថ ឬសេចក្តីដ៏ប្រសើរ។

# បរមត្ថធម៌ មាន ៤ គឺ ÷

១-ចិត្តបរមត្ថ បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង

២-ចេតសិកបរមត្ថ បានដល់ ចេតសិក ៥២

៣-រូបបរមត្ថ បានដល់ រូប ២៨

៤-និព្វានបរមត្ថ បានដល់ ព្រះនិព្វាន

# រូបបរមត្ថ
## បរិច្ឆេទទី ៦

### រូបបរមត្ថ (MATTER)

រូប មានវចនត្ថៈថា រុប្បតីតិ = រូបំ ឈ្មោះថា រូប ព្រោះអត្ថថា បែកធ្លាយ គឺ រមែងបែកធ្លាយ ដោយបច្ច័យដែលជាសត្រូវមាន ត្រជាក់ និងក្ដៅជាដើម ។

# លក្ខណាទិចតុក្កៈរបស់រូប

១ - រុប្បនលក្ខណំ    រូបមានការបែកធ្លាយ ជាលក្ខណៈ

២ - វិកិរណរសំ    មានការខ្ចាត់ខ្ចាយ (ឬមានការមិនដឹងអារម្មណ៍) ជាកិច្ច

៣ - អព្យាកតបច្ចុប្បដ្ឋានំ    មានភាពជាអព្យាកត ជាអាការប្រាកដ

៤ - វិញ្ញាណបទដ្ឋានំ    មានវិញ្ញាណ ជាបទដ្ឋាន ។

**រូបមាន ២៨ គឺ ៖** មហាភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ រួមជានិប្ផន្នរូប ១៨ ។

បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ និងលក្ខណរូប ៤ រួមជាអនិប្ផន្នរូប ១០ ។

រូបទាំង ២៨ ចែកជាប្រភេទធំៗមាន ២ គឺ មហាភូតរូប ៤ និង ឧបាទាយរូប ២៤ តែបើចែកដោយប្រភេទតូចៗ មានរូប ១១ ពួកដូចតទៅនេះ គឺ ៖

| | | |
|---|---|---|
| **១ - មហាភូតរូប ៤** | បានដល់ | **បឋវី អាបោ តេជោ វាយោ** |
| **២ - បសាទរូប ៥** | បានដល់ | **ចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ កាយបសាទ** |
| **៣ - វិសយរូប ៤** | បានដល់ | **វណ្ណៈ សទ្ទៈ គន្ធៈ រសៈ** |
| **៤ - ភាវរូប ២** | បានដល់ | **ឥត្ថីភាវៈ បុរិសភាវៈ** |
| **៥ - ហទយរូប ១** | បានដល់ | **ហទយវត្ថុ** |

| | | |
|---|---|---|
| ៦ - ជីវិតរូប ១ | បានដល់ | ជីវិតិន្ទ្រិយ |
| ៧ - អាហាររូប ១ | បានដល់ | កពឡិង្ការាហារ |
| ៨ - បរិច្ឆេទរូប ១ | បានដល់ | អាកាសធាតុ |
| ៩ - វិញ្ញត្តិរូប ២ | បានដល់ | កាយវិញ្ញត្តិ វចីវិញ្ញត្តិ |
| ១០ - វិការរូប ៣ | បានដល់ | លហុតា មុទុតា កម្មញ្ញតា |
| ១១ - លក្ខណរូប ៤ | បានដល់ | ឧបចយៈ សន្តតិ ជរតា អនិច្ចតា ។ |

បណ្ដារូប ២៨ នេះ ក្នុងបាលីចែកទុកជា ២ ពួក គឺ សភាវរូប ១ និង អសភាវរូប ១ ។

**សភាវរូប** បានដល់ មហាភូតរូប ៤ ប្រសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ ។

រូប ១៨ នេះ មានឈ្មោះហៅបាន ៥ យ៉ាង គឺ ៖

| | |
|---|---|
| ១ - **សភាវរូប** | រូបដែលមានភាវៈរបស់ខ្លួន |
| ២ - **សលក្ខណរូប** | រូបដែលមានលក្ខណៈ |
| ៣ - **និប្ផន្នរូប** | រូបដែលកើតអំពីសមុដ្ឋាន ៤ |
| ៤ - **រូបរូប** | រូបដែលបែកធ្លាយ |
| ៥ - **សម្មសនរូប** | រូបដែលគួរពិចារណា |

# ១ - បឋវីធាតុ (The earth-element)

បឋវីធាតុ មានលក្ខណៈ ២ គឺ ៖

**១ - កក្ខឡ បឋវី** បឋវីដែលមានភាពរឹង ជាលក្ខណៈ (Hardness)

**២ - អថទ្ធ បឋវី** បឋវីដែលមានភាពមិនរឹង ជាលក្ខណៈ (Softness)

**បឋវី** មានវចនត្ថៈថា ៖ **បត្ថីនត្ថេន = បឋវី** ឈ្មោះថា **បឋវី** ព្រោះអត្ថថា **រឹង** ។

ន័យមួយទៀត **សហជាតរូបានិ បឋន្តិ បតិដ្ឋហន្តិ ឯត្ថាតិ = បឋវី** ប្រែថាសហជាតរូបទាំងឡាយ រមែងអាស្រ័យ តាំងនៅក្នុងធាតុនេះ ព្រោះហេតុនោះធាតុនេះ ទើបឈ្មោះថា **បឋវី** ។




## លក្ខណាទិចតុក្កៈរបស់បឋវី

១ - កក្ខឡត្តលក្ខណា មានភាពរឹង ជាលក្ខណៈ

២ - បតិដ្ឋានរសា មានការតាំងមាំ ជាកិច្ច

៣ - សម្បដិច្ឆន្នបច្ចុប្បដ្ឋានា មានភាពជាទីទទួលរង ជាអាការប្រាកដ

៤ - អវសេសធាតុត្តយបទដ្ឋានា មានធាតុ ៣ ដែល នៅសល់ ជាហេតុជិត ។

# **បឋវីធាតុមាន ៤ យ៉ាង ៖**

**១ - បរមត្ថបឋវី** ឬ **លក្ខណបឋវី** បានដល់  ធាតុដីដែល

មានភាពរឹង ឬទន់ជាសភាវៈ

**២ - សសម្ភារបឋវី** ឬ **សុត្តន្តបឋវី** បានដល់ធាតុដីដែលមាន

ចំណែកប្រកប មានទាំងខាង

ក្នុងកាយ និងខាងក្រៅកាយ ។

រូបក្នុងកាយរបស់សត្វ ជាឧបាទិន្នរូប ហៅថា **អជ្ឈត្តិកបឋវី** ។

រូបខាងក្រៅកាយរបស់សត្វ ជាអនុបាទិន្នរូប ហៅថា **ពាហិរបឋវី** ។

អជ្ឈត្តិកបឋវី មាន ២០ ចែកជា ៤ ពួកគឺ ៖

## ពួកតចបញ្ចកៈ

១ - កេសា សក់

២ - លោមា រោម

៣ - នខា ក្រចក

៤ - ទន្តា ធ្មេញ

៥ - តចោ ស្បែក

## ពួកវក្កបញ្ចកៈ

៦ - មំសំ សាច់

៧ - នហារូ សរសៃ

៨ - អដ្ឋិ ឆ្អឹង

៩ - អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង

១០ - វក្កំ តម្រងបស្សាវៈ

## ពួកបប្ផាសបញ្ចកៈ

១១ - ហទយំ បេះដូង

១២ - យកនំ ថ្លើម

១៣ - កិលោមកំ វាវ

១៤ - បិហកំ ក្រពះ

១៥ - បប្ផាសំ សួត

## ពួកមត្ថលុង្គបញ្ចកៈ

១៦ - អន្តំ ពោះវៀនធំ

១៧ - អន្តគុណំ ពោះវៀនតូច

១៨ - ឧទរិយំ អាហារថ្មី

១៩ - ករីសំ អាហារចាស់

២០ - មត្ថលុង្គំ ខួរក្នុងក្បាល

**៣ហិរបរី** គឺ ធាតុដីខាងក្រៅ បានដល់ ធម្មជាតិដែលរឹង ជាអនុបាទិន្នរូបដូចជា **អយោ** ដែក; **លោហំ** លោហៈ; **តិបុ** សំណប៉ាហាំង; **សីសំ** សំណភក់; **សង្ឃ** ប្រាក់; **មុត្តា** កែវមុក្តា; **មណិ** កែវមណី ជាដើម ។

**៣ - កសិណបរី** ឬ **អារម្មណបរី** បានដល់ បបរីកសិណ ឬដី ដែលជា អារម្មណ៍របស់សមថកម្មដ្ឋាន ។

**៤ - សម្មុតិបរី** ឬ **បកតិបរី** បានដល់ ធាតុដីដែលសន្មត ហៅថា ដី ដុំដី ទីដី ផ្ទៃដី ផែនដី ។